ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១០២១ អយក.ប្រក

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់កម្មវិធីសិក្សា និងការផ្តល់តម្លៃសមមូលសញ្ញាបត្រកម្រិតមធ្យមសិក្សា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ មិថុនា ឆ្នាំ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងលិខិតក្រុមប្រឹក្សាភិបាល SOUTH AUSTRALIA CERTIFICATE OF EDUCATION (SACE) រដ្ឋអូស្ត្រាលីភាគខាងត្បូង នៃប្រទេសអូស្ត្រាលី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥

## សម្រេច

**ប្រការ១ .-**

ត្រូវបានទទួលស្គាល់កម្មវិធីសិក្សាអន្តរជាតិឈ្មោះ SOUTH AUSTRALIA CERTIFICATE OF EDUCATION ជាអក្សរកាត់ SACE នៃរដ្ឋអូស្ត្រាលីភាគខាងត្បូង ប្រទេសអូស្ត្រាលី។ កម្មវិធីសិក្សាអន្តរជាតិ SACE មានតម្លៃសមមូលស្មើនឹងកម្មវិធីសិក្សាចំណេះទូទៅជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ២ .-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនអន្តរជាតិដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងបានទទួលសិទ្ធិបណ្តុះបណ្តាលពីក្រុមប្រឹក្សាភិបាល SACE អាចធ្វើការបណ្តុះបណ្តាលកម្មវិធីសិក្សាចំណេះទូទៅអន្តរជាតិ SACE ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

សញ្ញាបត្របញ្ចប់ការសិក្សាកម្មវិធីសិក្សាអន្តរជាតិ SACE ត្រូវបានទទួលស្គាល់ និងមានតម្លៃសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា។ សិស្សានុសិស្ស ឬអ្នកសិក្សាដែលទទួលបានសញ្ញាបត្របញ្ចប់ការសិក្សាកម្មវិធីសិក្សាអន្តរជាតិ SACE អាចប្រើប្រាស់សញ្ញាបត្ររបស់ខ្លួនសម្រាប់បំពេញលក្ខខណ្ឌក្នុងការបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា តាមគ្រឹះស្ថានឧត្តមសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ .-**

ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិដកហូត ឬ បដិសេធសញ្ញាបត្របញ្ចប់ការសិក្សាកម្មវិធីសិក្សាអន្តរជាតិ SACE ក្នុងករណីត្រួតពិនិត្យរកឃើញមានភាពមិនត្រឹមត្រូវក្នុងដំណើរការសិក្សា ឬ មានភាពមិនត្រឹមត្រូវក្នុងការសម្រេចផ្តល់សញ្ញាបត្រដល់អ្នកសិក្សា។ គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនអន្តរជាតិដែលផ្តល់ការបណ្តុះបណ្តាលកម្មវិធីសិក្សាអន្តរជាតិ SACE ត្រូវរៀបចំបញ្ជីឈ្មោះសិស្សដែលបានប្រឡងជាប់ជាស្ថាពរនៅក្នុងកម្មវិធីប្រឡងបញ្ចប់ដោយភ្ជាប់មកជាមួយនូវពិន្ទុលទ្ធផលសិក្សារបស់សិស្ស ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងផ្តល់ការឯកភាពមុននឹងចេញវិញ្ញាបនបត្របណ្តោះអាសន្ន និង/ឬ បោះពុម្ពសញ្ញាបត្រជូនដល់សិស្សដែលបានប្រឡងជាប់ជាស្ថាពរ។ ករណីអ្នកសិក្សាដែលទទួលបានសញ្ញាបត្រកម្មវិធីសិក្សាអន្តរជាតិ SACE ពីបរទេស ត្រូវស្នើសុំធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវមកក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេចមុនយកទៅប្រើប្រាស់ជាផ្លូវការ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយក នៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយក នៃអគ្គនាយកដ្ឋានកីឡា អគ្គនាយក នៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការ

នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានកិច្ចការប្រឡង ប្រធាននាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ សាកលវិទ្យាធិការ និងនាយកគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈនិងឯកជន មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងក្រុមប្រឹក្សាភិបាល SACE ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី

«*ដើម្បីជូនជ្រាបជាព័ត៌មាន*»

- ដូចប្រការ ៦ «*ដើម្បីអនុវត្ត*»
- កាលប្បវត្តិ-ឯកសារ

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**